ស្ថានទូតអូស្ត្រាលីភ្នំពេញ

<u>សេចក្តីប្រកាសព័ត៌មាន</u>

# ការប្រកាសបើកទទួលពាក្យសុំ នៃកម្មវិធីជំនួយផ្ទាល់ ស្ថានទូតអូស្ត្រាលី ឆ្នាំ២០១៧

ពាក្យស្នើសុំសម្រាប់កម្មវិធីជំនួយផ្ទាល់អូស្ត្រាលី (DAP) ឆ្នាំ ២០១៧ ត្រូវបានប្រកាសបើកទទួលចាប់ពីពេលនេះទៅ។

ថវិកាជំនួយមានទឹកប្រាក់រហូតដល់ ៥៥.000 ដុល្លាអូស្ត្រាលី ក្នុងមួយគម្រោង នឹងត្រូវផ្តល់ជូនដល់អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជនដែលធ្វើការទាក់ទងនិងការជួយអភិវឌ្ឍន៍សហគមន៍ និងអង្គការដែលមិនទទួលប្រាក់កម្រៃ ផ្សេងទៀត ដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍សហាគមន៍ខ្នាតតូចនានា។

លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីបានមានប្រសាសន៍ថា "អូស្ត្រាលីមានមោទនភាពក្នុងការគាំទ្រដល់គម្រោងខ្នាតតូចនៅកម្ពុជា ដែលកំពុងជួយឲ្យមានការប្រែប្រួលយ៉ាងធំធែងដល់សហាគមន៍នានា" ។

លោកជំទាវបានបន្តទៀតថា "យើងមានសេចក្តីសប្បាយរីករាយក្នុងការបន្តឧបត្ថម្ភដល់កម្មវិធីនេះនាឆ្នាំ ២០១៧ ដែលវាជាចំណែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា"។

DAP នៅកម្ពុជា ជាកម្មវិធីមួយដែលមានការប្រកួតប្រជែងខ្ពស់។ ពាក្យសុំត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវមួយចំនួន ដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំ នៃការដាក់ពាក្យដោយមានដាក់ផ្សាយលើទំព័រវេបសាយ ស្ថានទូត អូស្ត្រាលី http:/cambodia.embassy.gov.au

ការបរិច្ឆេទបិទនៃការទទួលពាក្យស្នើសុំសង្ខេប (Express of Interest Form) ធ្វើនៅថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១៧។ ប្រសិនបើលោកអ្នកមានសំណួរផ្សេងៗអំពីដំណើរការនៃការដាក់ពាក្យសុំ សូមទាក់ទងតាមរយៈអ៊ីម៉ែល dap.phnompenh@dfat.gov.au

**ទំនាក់ទំនងពត៌មាន Australian.Embassy.Cambodia@dfat.gov.au**

**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧**